# សេចក្តីដាស់តឿនកុមារា - កុមារី

លោកវ៉ាយ - ប៉ុក ក្រមការ រៀបរៀងជាពាក្យកាព្យ

ជាតិចំរើនដោយអក្សរសាស្ត្រ	មានបទបែបល្បះតាមមាត្រា
សរសេរតាមជនជាតិខុសអក្ខរា	ប្រើខាងរាជការមេឃចុះអ័ព្ទ ។
ប្រែលោកភូមិភពស្រុកខេត្តខ័ណ្ឌ	ប្រែខ្លួនគ្រប់គ្រាន់ក្បួនប្រារព្ធ
ប្រែច្បាប់វិទ្យាទាំងថ្ងៃយប់	ទើបប្រទេសជប់មហាស៊ីវិល័យ ។
បណ្ឌិត្យបូរាណគ្រូអាចារ្យ	មាសពេជ្យរចនាភ្លឺប្រពៃ
គួរគិតអប់រំជាតិនិស្ស័យ	ឲ្យបានថ្លាថ្លៃអនាគត ។
ព្យាយាមប្រមូលបណ្ឌិត្យប្រាជ្ញ,	ខំយកស្នូកបាចអវិជ្ជាពត់
សតវត្សរ៍ដប់ប្រាំបួនកត់	ធីរៈប្រវត្តិក្បួនសៀវភៅ ។
អក្សរសាស្ត្រអតីតលំបាកស្រាវ	បូរាណខំជ្រាវមិនយល់ផ្លូវ
សម័យវ័ន្ទែអង្គរនៅ	សិលាចារិកជ្រៅជ្រៀតមិនជ្រាប ។
ថែមមានសង្គ្រាមចលាចល	កម្ពុជាសកលកង្វល់ដាប
ជាតិខ្មែរបានដល់ទុព្វលភាព	អក្សរសាស្ត្រពាបរកមិនយល់ ។
គួរគិតបកប្រែសៀវភៅរៀន	ចំណេះរបៀនក្រៅមណ្ឌល
វិទ្យាគ្រប់បែបលោកដំកល់	ដំកើងជាតិដល់ផលចំរើន ។
ខេមរាប្រុសស្រីខំរៀនសូត្រ	សោយអាហារល្វតលាស់ក្រវើន
ដំរេះចេះចាំប្រាជ្ញដាស់តឿន	នាំគ្នាត្រាច់ល្បឿនលាងមន្ទិល ។
ពូជឧស្សាហ៍ស្វាងសែងអាត្មាបាន	ធ្វើជាតិកល្យាណជាងពូជខ្ជិល
ទាបថោកវង្សត្រកូលពាលខូចខិល	ម្តេចកម្ពុជារំកិលទាន់សម័យ ។
មនុស្សម្នាក់ពុំអាចសម្រេចការ	ត្រូវធ្វើសាមគ្គាពលប្រស្រ័យ
ប្រុសស្រីក្មេងចាស់ជួយវីនិច្ឆ័យ	ទើបឆ្នៃបានឈ្នះពីហីនជាតិ ។
ធម្មតាសិលាអាស្រ័យដែក	ញែកភ្លើងបំបែកធ្វើចេញធាតុ
មនុស្សត្រូវពឹងមនុស្សប្រាជ្ញឱវាទ	សប្បុរសជាខ្នាតទើបពកខ្ទែង ។
គួរអប់រំកាព្យឃ្លោងបាទកវី	បទបែបពេញទីភ្លឺស្វាងសែង
ពាក្យពេចន៍ឃ្លោងឃ្លានិពន្ធតែង	ឲ្យចេញភ្លើងផ្សែងផ្សព្វលោកា ។
រុក្ខជាតិព្រឹក្សព្រៃកាប់មកភ្លាម	កុំភ្លេចឈូសនាមចាំងបន្ទារ
គូសបន្ទាត់ដាប់កែតាមប្រាថ្នា	ធ្វើគ្រឿងទព្វសម្ភារគ្រឹហាបាន ។

ព្យាយាមដំដែកសព្វទិវា    កើតជាងរចនាប៉ូវថៅថ្កាន
ប្រទេសថ្កើងប្រុសស្រីព្យាយាមប្រាណ    ប្រឹងប្រែងយកឋានសោភ័ណភព ។
គួររៀនវិទ្យាសាស្ត្រសម័យ    កាយវិការប្រស្រ័យចិត្តប្រារព្ធ
មនុស្សព្រឹក្សចិត្តសាស្ត្រចាកយប់    យោងជាតិប្រសប់ចម្រើនយស ។
យកសត្វភមរាជាឧបសម័យ    ធ្វើជាតិឲ្យថ្លៃសោភ័ណខ្ពស់
ជញ្ជាបយកកេសរគន្ធរស    រុករកស្វែងស្វះធ្វើសំបុក ។
កុំត្រាប់កង្កែបគុម្ពឈ្មូកនៅ    ត្រាប់កន្លង់ដៅផុតពីកលីយុគ
នៅឆ្ងាយហើរឈមដម្រង់មុខ    មកក្រេបរសសុខបានសួស្តី ។
កុំត្រាប់មេអំបៅត្រាច់សប្បាយ មិ    នយល់ខ្លឹមស្រាយធម៌វិន័យ
ត្រូវយកទទាចងនិស្ស័យ    លលកបច្ច័យឆ្វែលជុំទ្រុង ។
វិទ្យាសាស្ត្រអប់រំយូរកាល    កបចេះភ្លឺច្រាលយល់ក្រៅក្នុង
រកឃ្នាបប្រាជ្ញាផុតលិចលង់    ឡើងចាកភក់ផុងកើតប្រាជ្ញប្រាយ ។
ធម្មតាគ្រាប់ឈើក្នុងប្រថពី    ខំរើរក់រីញែកកកាយ
យល់សែងសុរិយាក្លាពីនាយ    ទើបផ្សាយដើមទងដុះដាលឡើង ។
ដើមដូងស្រូបយកទឹកល្អកក្រោម    ត្រាច់ដាក់ឈមត្រង់មិនព្រងើយ
ក្នុងរលាសាច់ផ្លែមិនខ្លាចនឿយ    ប្រែទឹកផ្អែមហើយហូរត្រជាក់ ។
គួររៀនប្រវត្តិសាស្ត្រខេមរា    ឲ្យជាតិថ្លៃថ្លាប្រាជ្ញាស្ម័គ្រ
គោកធ្លកព្រះថោងចិនឡាថ្នាក់    មហារាជព្រហ្មណ៍ជាក់វង្សវរ្ម័ន ។
សម័យហ្វូណាង់ស្តេចអង្គរ    ប្រាសាទបវរល្អថ្កើងថ្កាន
ពោរពាសពេញដែនដីទិព្វស្ថាន    នានាប្រទេសបានបបខ្លបខ្លាច ។
ពូជតាត្រសក់ផ្អែមគួរផ្អូកនឹក    កម្ពុជាគោកទឹកមហាអំណាច
មហារាជឧដុង្គភ្នំពេញអាច    ចូលភ្លើងមមាចនិទ្រាលក់ ។
ប្រវត្តិសាស្ត្រនាំគ្នាស្នេហាជាតិ    ព្យាយាមសង្វាតកុំងោកងក់
ក្មេងចាស់សញ្ជូរលឿនទៅមុខ    ញាំងក្លាហានទុកមរដកកេរ្តិ៍ ។
បើបានជាបាបលោកុត្តរ    បើស្វែងបុណ្យល្អនិព្វានេ
បើឡើងគិរីកុំរិះរេ    ព្យាយាមគ្នាន់គ្នេរកំពូលលើ ។
បើបានធ្វើស្រែច្រូតកាត់ស្រេច    បើប្រើកលល្បិចកុំស្ទាក់ស្ទើរ
បើចង់ស្ទួយជាតិឲ្យខំដើរ    ដំណើរនឿយហាត់ទុក្ខកុំគិត ។
បើចង់បានពេជ្រខំកកាយ    បើចង់ភ្លឺសាយចូលងងឹត

បើចង់បានសុខឲ្យហាត់ចិត្ត សាមគ្គីមូលមិត្តជាតិផុតមារ ។
បើធ្វើកិច្ចការបរាជ័យ ប្រឹងទាំងជើងដៃរងទុក្ខា
ចាត់ធ្វើម្តងទៀតមនោក្លៀវក្លា គង់សម្រេចប្រាថ្នាប្រយោជន៍ធំ ។
ពូជធារក្លាហានអប់រំក្មេង រុក្ខាព័ទ្ធពែងពីខ្ទីសំ
ចង់បានប្រាជ្ញាឲ្យខំដំ ញយ ៗ ប្រជុំផលញឹកញាប់ ។
គួររៀនចេះចាំលេខគនិត នព្វន្តគួរគិតយល់សព្វគ្រប់
ចេះក្រែលបានគ្រាន់ប្រាជ្ញប្រសប់ ប្រសើរក្នុងភពគង់ផុតភ័យ ។
បូរាណពោលថាវាចាឯក ខាងលេខជាទោតាមញាណញេយ្យ
ក្មេងចូរស្វាធ្យាយស្អាងនិស្ស័យ ចាស់ហើយយប់ថ្ងៃកុំភ្លេចប្រាណ ។
បើចំណេះជាប់ចេះបច្ចុប្បន្ន ផ្ចិតចេះគយគន់កបច្រើនស្ថាន
ចេះអនាគតតាមលំអាន ប្រោសមនុស្សឲ្យបានឋានសប្បុរស ។
ប្រទេសមានបុព្វបុរសនាំ ថែទាំទាល់ឃើញដល់ត្រើយកោះ
កោរកែប្រែជាតិកោសគិតស្មោះ ទើបផ្លោះផ្លាស់សម័យលោកា ។
ធ្វើការត្រូវត្រាប់អ្នកស្ទួចត្រើ ត្រួតនុយប្រស្រ័យអប្បមាទា
ស្ទង់មើលស្វាបគិតកលប្រាជ្ញា ស្រេចទាញមច្ឆាយកអាស្រ័យ ។
កុំឲ្យទុកចិត្តសត្វមនុស្សា លលូកលាតលាវិនិច្ឆ័យ
ចរិតមារយាទពាក្យបច្ច័យ ឲ្យយល់ថោកថ្លៃពាលបណ្ឌិត ។
គួររៀនភូមិសាស្ត្រកម្ពុជា ភាពជាតិអាត្មារាជការគិត
ចំនួនមនុស្សឈ្មោះក្រុងពិនិត្យ សេដ្ឋកិច្ចប្រព្រឹត្តទំនៀមស្រុក ។
ជាតិខ្មែរមិនស្គាល់កម្ពុជា ស្វាធ្យាយសាសនាតាមទំនុក
មិនដឹងពុទ្ធប្រវត្តិពូជកុក មិនស្គាល់បឹងថ្លុកទ្រនំខ្លួន ។
ស្គាល់ខ្លួន ៗ ឯងលំបាកផុត ស្គាល់ដទៃពុតខ្មែរចិនយួន
ស្គាល់ភពលោកមេឃភាពច្បាប់ក្បួន ស្គាល់លោកធមិស្ងួនលំបាកប្លែក ។
គួររៀនចងចាំប្រាជ្ញមេធី ឲ្យស្គាល់ពេញទីមនុស្សសត្វញែក
តក្កវិទ្យាស្វាធ្យាយសែក សេពសំទតមែកដើមឫសគល់ ។
ឆ្ងល់សង្ស័យនាំមានប្រាជ្ញា បើបានជាថាឲ្យមានផល
បើបានជាដើរខំឲ្យដល់ បើបានជាជល់កុំខ្លាចស្លាប់ ។
ឧស្សាហ៍ព្យាយាមទើបបានចេះ ចង់បេះផលាដាំប្រារព្វ
ហេតុមនុស្សសត្វងងិតយប់ បថមកល្បគ្រប់ស្គាប់មិនព្ទ ។

កលោកទឹកដីព្រៃព្រឹក្សា    កជាតិសាសនាយល់ស្វាក់ស្ទើរ
បើមានបាវព្រាយឲ្យចេះប្រើ    ប្រាជ្ញាដំណើរនាមរូបធាតុ ។
បញ្ចក្ខន្ធបំបែកញែកតាមការ    ឲ្យស្គាល់រូបនាមាតាមក្បួនខ្នាត
ចក្រវាឡតូចធំខំសង្វាត    លោកធាតុឱវាទឲ្យយល់ស្ដែង ។
គួររៀនវិទ្យាហោរាសាស្រ្ត    តារាឆ្កៀតឆ្លុះខំប្រឹងប្រែង
ស្គាល់ចរិតចរិយាផលភ្លើងផ្សែង    មេឃផ្កាយសំដែងរាសីចន្ទ្រ ។
ចូរប្រុសស្រីដែនកម្ពុជា    ស្រឡាញ់គ្រប់គ្នាវិទ្យាគ្រាន់
លោកធម៌និស្ស័យឲ្យបានទាន់    សម័យលោកកាន់កបចេស្ដា ។
ទើបហៅស្រឡាញ់មាតុភូមិ    សាមគ្គីព្រៀងព្រមស្អាងវិទ្យា
ស្រឡាញ់ជាតិទឹកដីព្រៃព្រឹក្សា    ស្រឡាញ់ពុទ្ធសាសនាបានថ្លាថ្លៃ ។
វិទ្យាជាប្រទីបផុះប្រាជ្ញា    ធ្វើជនខេមរាថ្កើងយប់ថ្ងៃ
វិទ្យាកបគុណល្អប្រពៃ    ប្រាជ្ញាបណ្ឌិតចរណៃដំកើងជាតិ ។
នារីរតន៍បុរសអាជានេយ្យ    ដឹកនាំប្រស្រ័យខ្មែរឆ្លៀវឆ្លាត
ទើបឆ្លុះសិរីត្រកូលញាតិ    សួស្ដីលោកធាតុល្បីអស្ចារ្យ ។
វិទ្យាជាបិតារចនាគ្រប់    រដ្ឋាភិបាលសព្វតាមឋានា
សង្គមដុះដាលរៀបរាជការ    នយោបាយខេមរាចំរើនសុខ ។
កែប្រែខ្មែរឲ្យទាន់កាល    មានរស្មីភ្លឺច្រាលផុតពីទុក្ខ
កែទឹកដីសាសនាតាមទំនុក    ជាតិចេញចាកភក់ភពស៊ីវិល័យ ។
កែមតិទិដ្ឋិជនជាតិបាន    កែចរិយាឈានត្រាច់យប់ថ្ងៃ
ចំរើនសោភ័ណឆ្លងជលាល័យ    នាវាសុវណ្ណជ័យដល់ត្រើយត្រាន ។
កង់លោកវិលសព្វគ្រប់ទិវា    ជនជាតិខេមរាវិលគ្រប់ប្រាណ
ប្រឹងប្រែងព្យាយាមកុំអាក់ខាន    ដល់ស្ថានឯករាជ្យប្រជាធិបតេយ្យអើយ ។

**អត្ថបទកំណាព្យដកស្រង់ចេញពីគេហទំព័រវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ**

www.budinst.gov.kh

**ភិក្ខុវណ្ណគុត្តោ ស្វាត សាលឿម**

www.bodhikaram.com